International
Finance Corporation
World Bank Group

# សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និង មីក្រូហិរញ្ញវត្ថុ
# ទិដ្ឋភាពទូទៅ និងទិសដៅយុទ្ធសាស្ត្រ

ភ្នំពេញ — កម្ពុជា

ខែសីហា ឆ្នាំ ២០០៩

# សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ( IFC )

- សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិជាផ្នែកវិស័យឯកជនរបស់ក្រុមធនាគារពិភពលោក និងមានប្រទេសជាសមាជិកចំនួន ១៨១
- សាជីវកម្មនេះមានគោលដៅពង្រីងវិស័យឯកជននៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ តាមរយៈប្រាក់កម្ចី ហ៊ុន ហិរញ្ញវត្ថុដែលរៀបចំជារចនាសម្ព័ន្ធ និងសេវាប្រឹក្សា ជាដើម
- បេសកកម្មរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិគឺជម្រុញវិនិយោគដែលមាននិរន្តរភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ កាត់បន្ថយភាពក្រីក្រ និងលើកកំពស់ជីវភាពរបស់ប្រជាជន តាមរយៈ
  - ការផ្តល់ហិរញ្ញប្បទានលើការវិនិយោគរបស់វិស័យឯកជន
  - កៀងគរមូលធនឯកជននៅក្នុងទីផ្សារហិរញ្ញវត្ថុក្នុងស្រុក និងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ
  - ផ្តល់សេវាប្រឹក្សា និងសេវាកាត់បន្ថយហានិភ័យចំពោះអាជីវកម្ម និងរដ្ឋាភិបាលនានា
- នៅឆ្នាំហិរញ្ញកិច្ច ២០០៨ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិបានសន្យាផ្តល់ទឹកប្រាក់ ១១,៤ ពាន់លានដុល្លារអាមេរិក និងបានកៀងគរប្រាក់បន្ថែមចំនួន ៤,៨ ពាន់លានដុល្លារអាមេរិក តាមរយៈការចូលរួមក្នុងជាប្រាក់កម្ចី និងហិរញ្ញវត្ថុដែលត្រូវបានរៀបចំរចនាសម្ព័ន្ធសម្រាប់ការវិនិយោគ ចំនួន ៣៧២ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ចំនួន ៨៥ ។
- សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិនឹងរួមចំណែក ៥-២០ភាគរយជាការវិនិយោគលើហ៊ុន និងរក្សាការវិនិយោគសម្រាប់រយៈពេល ៨ ទៅ ១៥ ឆ្នាំ
- សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិជាស្ថាប័នស្វែងរកប្រាក់ចំណេញ យកអត្រាការប្រាក់ទីផ្សារចំពោះផលិតផល និងសេវាកម្មរបស់ខ្លួន
- សញ្ញាប័ណ្ណរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ជាសញ្ញាប័ណ្ណពេញនិយមនៅលើពិភពលោក មានតម្រូវការច្រើន និងមានទទួលចំណាត់ថ្នាក់ខ្ពស់បំផុត (AAA/Aaa) ពីស្ថាប័នចាត់ថ្នាក់ **by** Moody's, S&P និង Fitch ។

# គោលដៅ៖  ពង្រីកវិសាលភាពនិងបរិមាណនៃមីក្រូហិរញ្ញវត្ថុដែលមាននិរន្តរភាព







IS + AS រឹងមាំ  គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមាននិរន្តរភាព

មូលធនរបស់ឯកជនវិនិយោគតែទៅលើ
អាជីវកម្មដែលផ្តល់ផលចំណេញតែប៉ុណ្ណោះ

ធនធានរបស់វិស័យឯកជនមានសារៈសំខាន់ជាខ្លាំងចំពោះនិរន្តរភាព
នៃ មីក្រូហិរញ្ញវត្ថុខ្នាតធំ

មានតែគម្រោងខ្នាតធំតែប៉ុណ្ណោះ = វិសាលភាព និងបរិមាណច្រើន = ឥទ្ធិពលអភិវឌ្ឍន៍ត្រឹមត្រូវ

ឆ្លើយតបនឹងតម្រូវការរបស់ពិភពលោកចំនួន ៥ ភាគរយ ។ មានមនុស្ស ២,៥ ពាន់លាននាក់ត្រូវការ A2F
មិនអាចឆ្លើយតបតម្រូវការឥណទាន  សញ្ជ័យ សេវាផ្ទេរប្រាក់/ទូទាត់ ចំនួន ៣00 ពាន់លានដុល្លារ

# ធ្វើការជាមួយ IBRD និង CGAP ដើម្បីធ្វើឱ្យមានឥទ្ធិពល



# ដំណោះស្រាយយុទ្ធសាស្ត្រសំខាន់ៗចំនួនបួន

១. ជម្រុញមធ្យោបាយវិនិយោគរួមគ្នា (ហិរញ្ញវត្ថុ បំណុល និងមូលនិធិវិនិយោគលើស្តុក ដែលបានរៀបចំរចនាសម្ព័ន្ធ)

២. អភិវឌ្ឍដៃគូបណ្តាញមីក្រូហិរញ្ញវត្ថុ

៣. គាំទ្រគ្រឹះស្ថានហិរញ្ញវត្ថុឯកត្តជន តាមរយៈភាពជាដៃគូយុទ្ធសាស្ត្រ (ពោលគឺជាមួយកម្មវិធី នៅអាហ្វ្រិកក្នុងការអភិវឌ្ឍតំបន់មិនទាន់អភិវឌ្ឍ)

៤. ចូលរួមក្នុងគម្រោងសេវាប្រឹក្សាមួយចំនួននៅកម្រិតស្ថាប័ន កម្រិតហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ និងកម្រិតគោលនយោបាយ



# ផលប័ត្រមីក្រូហិរញ្ញវត្ថុដែលបានសន្យាដោយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ




- នៅឆ្នាំហិរញ្ញកិច្ច ២០០៨ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិបប្រើអតិថិជនប្រមាណជា ២០ លាននាក់
- ប្រមាណជា ៦៥ ភាគរយនៃអ្នកខ្ចីគឺជាស្ត្រី
- នៅខែ មិថុនា ឆ្នាំ ២០០៩ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិបានសន្យាផលប័ត្រវិនិយោគជា៍ ពាន់លានដុល្លារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាង ១៤០ នៅក្នុងប្រទេសជាង ៦០
- ទឹកប្រាក់ជាង ៧០ លានដុល្លារចំណាយលើសេវាប្រឹក្សាចំនួន ៤៥ភាគរយ នៃអតិថិជនជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

# ទិដ្ឋភាពរួមនៃឧស្សាហកម្មមីក្រូហិរញ្ញវត្ថុ










**Source:** Based on data from MIX Publications. "Selected Microfinance Indicators – 2006." May 5, 2008. Underlying data available online at:http://www.mixmbb.org/Publications/001-IND/02-IND.DATA/MFI%20INDUSTRY%20DATA%20SETS/Selected%20MF%20Indicators.pdf

# វិបត្តិហិរញ្ញវត្ថុពិភពលោក — ភាពងាយវិលមករកសភាពដើមនៃមីក្រូហិរញ្ញវត្ថុ?




- **ផ្នែកទ្រព្យសកម្ម:** សហគ្រិនមួយដ៏តូច អាចប្តូរយ៉ាងឆាប់រហ័សពីអាជីវកម្មអ្នកដេរស្បែកជើងទៅជា កន្លែងលក់ដូរគ្រឿងបរិភោគនៅក្នុងភូមិ
- **ផ្នែកទ្រព្យអកម្ម:** MFIS ចូលរួមជាមួយទីផ្សារទុន ក្នុងស្រុក និងបរិទេសនឹងជួបឧបសគ្គលើការផ្តល់មូលនិធិ ភាគច្រើននៅឆ្នាំ ២០១០
- **កង្វះការបន្តផ្តល់មូលនិធិ:** ធ្វើឱ្យប៉ះពាល់ដល់កំណើនផលប័ត្រវិនិយោគ
- ជារួមមាននិន្នាការកើនឡើងជាបណ្តើរៗនូវបំណុលមិនអាចសងបាន ទោះបីជាមានតិចជាងធនាគារក្តី

# វិបត្តិហិរញ្ញវត្ថុពិភពលោក_មេរៀនដែលបានរៀនសូត្រ

- **ការធ្វើអាជីវកម្មដែលមានចរិតអសីលធម៌ និងកេងប្រវ័ញ្ច**ចំពោះអតិថិជនជាការរួមចំណែកចំពោះវិបត្តិ (ឧទាហរណ៏៖ ទីផ្សារឥណទានដែលផ្តល់ឱ្យអ្នកមានប្រវត្តិឥណទានមិនល្អនៅសហរដ្ឋអាមេរិក ជាដើម)
- **ខ្វះតម្លាភាព និងខ្វះការបញ្ចេញព័ត៌មាន** ធ្វើឱ្យជួបការលំបាកក្នុងការវាយតម្លៃ និងកំណត់ថ្លៃហានិភ័យនៅទូទាំងប្រព័ន្ធហិរញ្ញវត្ថុ
- អតិថិជនមិនយល់អំពីកាលកំណត់ឥណទាន ហើយជាញឹកញាប់ផ្សងខ្លួនជាមួយនឹងការជំពាក់បំណុលគេច្រើនហួស

# កម្លាំងជម្រុញថ្មីសម្រាប់ហិរញ្ញវត្ថុដែលមានការទទួលខុសត្រូវ

យុទ្ធសាស្រ្តមីក្រូហិរញ្ញវត្ថុរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិសម្រាប់ហិរញ្ញវត្ថុដែលមានការទទួលខុសត្រូវ រួមមានៈ

១. ធ្វើយ៉ាងណាឱ្យ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនផ្តល់ឥណទានចំពោះសកម្មភាពសេដ្ឋកិច្ចដែលផ្តល់ផលិតភាព និងពុំមែនសម្រាប់ប្រើប្រាស់មិនចាំបាច់ ដែលធ្វើឱ្យកើនឡើងនូវភាពជំពាក់បំណុលមិនសមស្រប

២. ធ្វើយ៉ាងណាឱ្យអតិថិជនទាំងឡាយអនុលោមតាមបញ្ជីផាត់ចេញរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ

៣. ធ្វើយ៉ាងណាឱ្យការអនុវត្តមានតម្លាភាព (ដូចជា ការបោះផ្សាយអត្រាការប្រាក់ប្រសិទ្ធ ជាដើម)

៤. ផ្តោតលើគុណភាពនៃផលប័ត្រវិនិយោគ ហេតុនេះការឱ្យខ្ចីត្រូវវិភាគ និងពិចារណាឱ្យម៉ត់ចត់

សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិចាប់ដៃគូជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុណាដែលមានទស្សនវិស័យពាណិជ្ជកម្មក្នុងការផ្តល់ឥណទាន ហើយពិនិត្យមើលចំណងទាក់ទងរយៈពេលវែងជាមួយអ្នកខ្ចី ព្រមទាំងជួយសម្រួលកំណើននៃសកម្មភាពផលិតរបស់ពួកគេ។